*សកម្មភាពរួម ដំណោះស្រាយរួម*

# បញ្ហាគ្រប់គ្រងទឹកឆ្លងដែនក្នុងអាង ទន្លេសេសាន និង ទន្លេស្រែពក

## កិច្ចសហការរវាងកម្ពុជានិងវៀតណាម

ព័ត៌មានសង្ខេបអំពីគម្រោង
គ្រប់គ្រងធនធានទឹកចម្រុះ








ទន្លេសេសាន និង ទន្លេស្រែពក ដែលជាដៃទន្លេធំៗចំនួនពីរ នៃខ្សែទឹកខាងក្រោមនៃអាងទន្លេមេគង្គ ហូរកាត់ប្រទេសកម្ពុជាផង និង ប្រទេសវៀតណាមផង។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ មានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ក្នុងតំបន់អាងទន្លេទាំងពីរដូចជា វារីអគ្គីសនី ការធ្វើអាជីវកម្មរ៉ែ ប្រព័ន្ធស្រោចស្រពកសិកម្មនិងការកាប់ឈើជាដើម។ការអភិវឌ្ឍន៍បែបនេះ បង្កឲ្យមានគ្រោះទឹកជំនន់ ទឹកភ្លៀង គ្រោះរាំងស្ងួត ការថយចុះនូវទិន្នផលត្រី ការផ្លាស់ប្តូររបបលំហូរទឹកទន្លេ ការបំពុលបរិស្ថាន ការបាត់បង់ជីវៈចម្រុះ និង បញ្ហាដទៃទៀត ដែលបង្កផលប៉ះពាល់ដល់សហគមន៍មូលដ្ឋានក្នុងប្រទេសទាំងពីរ។

ដើម្បីគ្រប់គ្រងធនធានរួមក្នុងអាងទន្លេទាំងពីរនេះ ខណៈដែលធ្វើឲ្យមានការកាត់បន្ថយផលប៉ះពាល់ ដែលបង្កឡើងដោយការអភិវឌ្ឍន៍ឲ្យនៅត្រឹមកម្រិតអប្បបរមា ប្រទេសកម្ពុជា និងវៀតណាម កំពុងពង្រឹងកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ តាមរយៈគម្រោងទ្វេភាគី ដែលទទួលបានការគាំទ្រពីគណកម្មការទន្លេមេគង្គ (MRC)។

បន្ទាប់ពីបានចុះប្រមូលទិន្នន័យដល់មូលដ្ឋាន និង ពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាល និង តួអង្គពាក់ព័ន្ធនៅមូលដ្ឋានរួចមក ប្រទេសកម្ពុជា និង វៀតណាម បានកំណត់បញ្ហាជាក់លាក់ជាអាទិភាពចំនួនប្រាំមួយសម្រាប់ការសហការនិងសហប្រតិបត្តិការឆ្លងដែន។

## ព័ត៌មានសង្ខេបអំពីគម្រោង ទន្លេសេសាននិងស្រែពក

គម្រោងគ្រប់គ្រងធនធានទឹកក្នុងអាងទន្លេសេសាន និងទន្លេស្រែពក គឺជាគំនិតផ្តួចផ្តើមមួយ ក្នុងចំណោមគំនិតផ្តួចផ្តើមទ្វេភាគីទាំង ៥ របស់គណៈកម្មការទន្លេមេគង្គ ដើម្បីឆ្លើយតបទៅលើបញ្ហារៀបចំផែនការគ្រប់គ្រងធនធានទឹកឆ្លងដែនតាមរយៈកិច្ចសហប្រតិបត្តិការ។ ដោយទទួលបានមូលនិធិពីធនាគារពិភពលោក គម្រោងនេះ ជម្រុញឲ្យមានការសម្របសម្រួលការអនុវត្តសកម្មភាព ស្របតាមគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលជាទស្សនទានសកលមានគោលបំណងធ្វើឲ្យមានតុល្យភាពរវាងតម្រូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងការការពារបរិស្ថានក្នុងសហគមន៍តាមដងទន្លេ។ គម្រោងនេះនឹងបំពាក់បំប៉នប្រទេសទាំង២ នូវសមត្ថភាព និង ឧបករណ៍ ដើម្បីបន្តអនុវត្តសកម្មភាពរួមគ្នាក្រោយគម្រោងនេះបញ្ចប់។

# បញ្ហាគ្រប់គ្រងធនធានទឹកឆ្លងដែន ជាអាទិភាព៖

បញ្ហាទាំងប្រាំមួយខាងលើ ត្រូវបានពិពណ៌នានៅក្នុងឯកសារបច្ចេកទេសរួមគ្នាមួយ ដែលមានចំណងជើងថា *បញ្ហាគ្រប់គ្រងធនធានទឹកឆ្លងដែនក្នុងអាងទន្លេសេសាន និង ទន្លេស្រែពកនៃប្រទេសកម្ពុជា និងវៀតណាម* ដែលបានបោះពុម្ពផ្សាយកាលពីខែ កញ្ញា ឆ្នាំ ២០១៧។







១ **ការពិនិត្យតាមដាន និង វាយតម្លៃរបបលំហូរទឹកទន្លេ៖** ពុំមានប្រទេសណាមួយក្នុងចំណោមប្រទេសទាំងពីរនេះ ធ្លាប់បានធ្វើការវាយតម្លៃលើធនធានទឹក និងសេណារីយ៉ូនៃការអភិវឌ្ឍន៍នៅតំបន់ខ្សែទឹកខាងលើទន្លេ ដើម្បីស្វែងយល់ឲ្យបានកាន់តែច្បាស់អំពីផលប៉ះពាល់ ដែលអាចកើតមានឡើងដោយសារសកម្មភាពវារីអគ្គិសនីមកលើអាងទន្លេសេសាន និងស្រែពកទាំងមូលនោះឡើយ។ ទិន្នន័យធនធានទឹករយៈពេលវែង (ដូចជា កម្ពស់ទឹក ការបញ្ចេញទឹក កម្ពស់ទឹកភ្លៀង គុណភាពទឹក ជាដើម) នៃអាងទន្លេទាំងមូលជាទូទៅពុំមានភាពស៊ីសង្វាក់គ្នា និងមិនអាចជឿទុកចិត្តបានឡើយ។ ប្រទេសទាំងពីរចាំបាច់ត្រូវពង្រឹងដំណើរការពិនិត្យតាមដាន និង វាយតម្លៃលើធនធានទឹករបស់ខ្លួនសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត និង ការអភិវឌ្ឍន៍អាងទន្លេទាំងពីរ ឲ្យមាននិរន្តរភាពសម្រាប់រយៈពេលវែង។

២ **យន្តការព្យាករណ៍ និង ប្រកាសអាសន្នអំពីកម្ពស់ទឹកជំនន់៖** ប្រទេសទាំងពីរ ចេញផ្សាយព័ត៌មានព្យាករណ៍កម្ពស់ទឹកជំនន់ និង ការប្រកាសអាសន្នតែក្នុងដែនដីរបស់ខ្លួនប៉ុណ្ណោះ ហើយប្រទេសទាំងពីរ ក៏ធ្វើការផ្លាស់ប្តូរព័ត៌មានអំពីកម្ពស់ទឹកភ្លៀង និង សកម្មភាពទំនប់វារីអគ្គិសនីត្រឹមកម្រិតរដ្ឋាភិបាលដែរ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋាន និង សហគមន៍ពាក់ព័ន្ធ មានការលំបាកក្នុងការទទួលបានព័ត៌មាននេះសម្រាប់ធ្វើការព្យាករណ៍ និង ប្រកាសអាសន្នជាមុនអំពីកម្ពស់ទឹកជំនន់ឆ្លងដែន។ ប្រការនេះ នាំឲ្យមានការកើតឡើងនូវគ្រោះទឹកជំនន់ដោយមិនបានរំពឹងទុកជាមុន និង បង្កការខូតខាតដល់តំបន់ដែលស្ថិតនៅខ្សែទឹកខាងក្រោម និង ធ្វើឲ្យកម្ពស់ទឹកនៅខ្សែទឹកខាងលើទាបជាងកម្រិតធម្មតា ដែលអាចបង្កផលប៉ះពាល់ដល់ការផលិតថាមពលនារដូវប្រាំងបន្ទាប់។ ប្រទេសទាំងពីរ ត្រូវការប្រព័ន្ធព្យាករណ៍ទឹកជំនន់ និងយន្តការផ្លាស់ប្តូរទិន្នន័យដែលមានប្រសិទ្ធភាព សម្រាប់ធ្វើការប្រកាសអាសន្នជាមុន និងត្រូវផ្សព្វផ្សាយព័ត៌មាននេះឲ្យទាន់ពេលវេលាដល់សហគមន៍។

៣ **យន្តការទំនាក់ទំនងនិងចែករំលែកព័ត៌មាន៖** ប្រទេសកម្ពុជា និងវៀតណាម ខិតខំបង្កើតប្រព័ន្ធប្រកាសអាសន្នជាមុនជាលក្ខណៈឆ្លងដែន ដែលជូនដំណឹងពីការបញ្ចេញទឹកពីទំនប់វារីអគ្គិសនី ប៉ុន្តែកន្លងមកនេះប្រព័ន្ធទាំងនេះពុំមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធឲ្យបានទាន់ពេលវេលាដល់សហគមន៍ដែលរងផលប៉ះពាល់ឡើយ។ ជាមួយនឹងការអភិវឌ្ឍន៍រោងចក្រវារីអគ្គិសនីជាបន្តបន្ទាប់នៅក្នុងទន្លេសេសាន និងទន្លេស្រែពក ប្រទេសទាំងពីរ ចាំបាច់ត្រូវតែបង្កើតនូវប្រព័ន្ធព្យាករណ៍ទឹកជំនន់ ដែលមានប្រសិទ្ធភាព និង យន្តការផ្លាស់ប្តូរទិន្នន័យឲ្យបានគ្រប់គ្រាន់ ដើម្បីបង្កលក្ខណៈឲ្យមានការប្រកាសអាសន្នជាមុន និងផ្សព្វផ្សាយព័ត៌មានដល់សហគមន៍មូលដ្ឋានឲ្យបានទាន់ពេលវេលា។

**ប្រទេស៖**
កម្ពុជា និង វៀតណាម

**ថវិកា៖**
៣៥៤.០០០ ដុល្លារ

**រយៈពេល៖**
ពីខែឧសភា ឆ្នាំ២០១៤ ដល់ ខែមិនា ឆ្នាំ២០១៨

៤ **វិធានការកាត់បន្ថយផលប៉ះពាល់ ដែលបង្កឡើងដោយការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី៖** គម្រោងថាមពលវារីអគ្គីសនីកន្លងមក ការធ្វើកសិកម្មបែបប្រពលវប្បកម្ម និងសកម្មភាពដទៃទៀតនៅអាងទន្លេសេសាន និងអាងទន្លេស្រែពក ត្រូវបានធ្វើឡើងដោយពុំបានគិតគូរពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់សង្គម និង បរិស្ថានឆ្លងដែន ដូចជា ការថយចុះនូវទិន្នផលនេសាទ ការទទួលបានទឹកស្អាតនិងមានសុវត្ថិភាព និងការបាក់ដីច្រាំងទន្លេជាដើម។ ប្រសិនបើពុំមានការវាយតម្លៃអាងទន្លេទាំងមូលឲ្យបានត្រឹមត្រូវនោះទេ គេមិនអាចដាក់ឲ្យអនុវត្តវិធានការកាត់បន្ថយ និង ទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានបានឡើយ។ ប្រទេសទាំងពីរ ចាំបាច់ត្រូវបង្កើតនូវឧបករណ៍កំណត់ពីវិធានការដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ។



៥ **សមត្ថភាពស្ថាប័នសម្រាប់ធ្វើការសម្របសម្រួលឆ្លងដែន៖** ប្រទេសកម្ពុជា និងវៀតណាម ខ្វះអ្នកឯកទេសខាងជលសាស្ត្រ អ្នកឯកទេសខាងបរិស្ថាន អ្នកបង្កើតម៉ូឌែលវិស្វករធារាសាស្ត្រ និងអ្នករៀបចំផែនការធនធានទឹក។ ប្រទេសទាំងពីរ ក៏ខ្វះចំណេះដឹងគ្រប់គ្រង និងបច្ចេកទេស និងមានបទពិសោធន៏តិចតួច ក្នុងការចរចាការគ្រប់គ្រងធនធានទឹកឆ្លងដែនផងដែរ។ ប្រទេសទាំងពីរ ចាំបាច់ត្រូវកសាងសមត្ថភាពបុគ្គលិកផ្នែកការប្រមូលនិងវិភាគទិន្នន័យ ការបង្កើតម៉ូឌែល ការព្យាករណ៍ ការវាយតម្លៃផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។



៦ **ការជម្រុញឲ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធ និង ការបង្កើនការយល់ដឹងអំពីការគ្រប់គ្រងធនធានទឹក៖** ការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីនៅខ្សែទឹកខាងលើ មានការចូលរួមតិចតួចបំផុតពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកសិក្សាស្រាវជ្រាវ ដែលធ្វើឲ្យប្រជាពលរដ្ឋរស់នៅតំបន់ខ្សែទឹកខាងក្រោម ពុំបានដឹងពីផលប៉ះពាល់ ដែលអាចកើតមាន ដូចជា ទឹកជំនន់ភ្លាមៗ ការបំពុលបរិស្ថាន និងការថមថយគុណភាពទឹក នោះឡើយ។ ជាការសំខាន់ណាស់ ដែលត្រូវមានការចាត់វិធានការបង្កើនការយល់ដឹង និង ធានាឲ្យមានការចូលរួមក្នុងលក្ខណៈស្ថាបនាពីតួអង្គពាក់ព័ន្ធនៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត (ដូចជា ការរៀបចំផែនការ និងការគ្រប់គ្រង ជាដើម)។



## សកម្មភាពទ្វេភាគី ៖

ប្រទេសកម្ពុជា និង ប្រទេសវៀតណាម បានឯកភាពគ្នាចាត់វិធានការជាជំហានៗជាច្រើន ដើម្បីឆ្លើយតបចំពោះបញ្ហាឆ្លងដែនជាអាទិភាព តាមរយៈគម្រោងទ្វេភាគីនេះ ៖

១. បង្កើតយន្តការសម្របសម្រួលឆ្លងដែន ដើម្បីលើកកម្ពស់ការចែករំលែកទិន្នន័យ និងការគ្រប់គ្រងធនធានទឹករួមគ្នា

២. រៀបចំផែនការសកម្មភាពរួមមួយ ដើម្បីអនុវត្តយន្តការសម្របសម្រួលទាំងនេះ

បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់ គេរំពឹងថាប្រទេសទាំងពីរ នឹងអាចបន្តកិច្ចពិគ្រោះយោបល់ឆ្លងដែននិងអនុវត្តសកម្មភាពដែលគ្រោងទុកទាំងនេះ។កិច្ចខិតខំប្រឹងប្រែងរយៈពេលវែងទាំងនេះ នឹងជួយលើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់គ្រងធនធានទឹកឆ្លងដែនទ្វេភាគីនៅថ្នាក់ខេត្ត និង ត្រៀមលក្ខណៈប្រជាពលរដ្ឋនៅមូលដ្ឋាន នៅពេលដែលមានការអភិវឌ្ឍន៍ថែមទៀតនាពេលអនាគត។


## លេខាធិការដ្ឋាន
## គណៈកម្មការទន្លេមេគង្គ

អាគារលេខ ១៨៤ ផ្លូវ ហ្វាង្ហូម
ប្រអប់សំបុត្រលេខ ៦១០១
ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ

ទូរស័ព្ទ: +៨៥៦ ២១ ២៦៣២៦៣

ទូរសារ: +៨៥៦ ២១ ២៦៣៣៦៤

អ៊ីម៉ែល: mrcs@mrcmekong.org

គេហទំព័រ: www.mrcmekong.org

MEKONG RIVER COMMISSION

MRC

FOR SUSTAINABLE DEVELOPMENT

© រក្សាសិទ្ធិគ្រប់យ៉ាងដោយគណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១៧